UNITED NATIONS

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍យូភីអ ជុំទី៣ របស់ប្រទេសកម្ពុជា ទាក់ទងនឹងលម្ហសេរីភាពមូលដ្ឋាន

## តើដំណើរការពិនិត្យជាសកលតាមកាលកំណត់ ជាអ្វី?

ដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអ») គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិដែលមានអាណត្តិពិនិត្យកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ។ យន្តការ យូភីអ ជាដំណើរការដឹកនាំដោយរដ្ឋ ដែលរដ្ឋនីមួយៗប្រកាសអំពីវិធានការដែលរដ្ឋបានអនុវត្ត និងការបំពេញកាតព្វកិច្ចក្នុងការធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសរបស់របស់ខ្លួនបានល្អប្រសើរ។ ប្រទេសកម្ពុជាត្រូវបានពិនិត្យដោយយន្តការ យូភីអ នេះ ក្នុងខែមករា ឆ្នាំ២០១៩ ដែលរដ្ឋសមាជិកបានផ្តល់អនុសាសន៍ចំនួន១៩៨ ហើយប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួន១៧៣ និងកត់សម្គាល់ចំនួន ២៥ អនុសាសន៍ ដោយមានការអនុម័តរបាយការណ៍លទ្ធផលនៃការពិនិត្យដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងកិច្ចប្រជុំលើកទី៤១ ក្នុងខែកក្កដា ឆ្នាំ២០១៩។ នៅក្នុងជុំទី៣ នេះ មានអនុសាសន៍កើនឡើង៦%បើប្រៀបធៀបទៅនឹងជុំទី២។

## ខាងក្រោមគឺជាអនុសាសន៍ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក៖

១ ចាត់វិធានការចាំបាច់នានាដើម្បីអនុញ្ញាតឱ្យសមាជិកគណបក្សជំទាស់ចូលរួមក្នុងជីវភាពនយោបាយកម្ពុជាឡើងវិញ។ (បារាំង)

២ ចាត់វាល់វិធានការក្នុងការការពារ និងគាំទ្រដល់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស កម្មករសហជីព សកម្មជន ដីធ្លីនិងបរិស្ថាន និងតួអង្គសង្គមស៊ីវិលដទៃទៀត ព្រមទាំងសមាជិកគណបក្សជំទាស់។ (អ៊ីស្លង់)

៣ បង្កើតលក្ខខណ្ឌចាំបាច់ផ្សេងៗ ដើម្បីអនុញ្ញាតឱ្យបុគ្គលគ្រប់រូបទទួលបាននូវសិទ្ធិជាមូលដ្ឋាន ជាពិសេស សេរីភាពបញ្ចេញមតិ សមាគម និងការប្រមូលផ្តុំដោយសន្តិវិធី តាមរយៈការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ជាពិសេស ដើម្បីការពារអ្នកការពារសិទ្ធិមនុស្សពីផ្តន្ទាទោសដោយសារការអនុវត្តសិទ្ធិមូលដ្ឋានរបស់ខ្លួនក្រោមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍។ (កូស្តារីកា-អេស្បាញ)

៤ ស្តារឡើងវិញនូវលំហប្រជាធិបតេយ្យ និងនយោបាយ ដោយធានានូវការចូលរួមសម្រាប់គណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ (ន័រវែស)

៥ បង្កើតលក្ខខណ្ឌផ្សេងៗ ដែលអំណោយផលដល់ការតស៊ូមតិ និងការប្រកួតប្រជែងនយោបាយដោយសេរី ដើម្បីកសាងឡើងវិញនូវលទ្ធិប្រជាធិបតេយ្យមួយ ដែលក្នុងនោះប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល រួមទាំងអ្នកការពារសិទ្ធិមនុស្ស អាចបំពេញការងាររបស់ខ្លួនដោយគ្មានការជ្រៀតជ្រែក ឬរារាំង។ (អ៊ីស្លង់)

៦ ពង្រឹងការចូលរួមបែបប្រជាធិបតេយ្យ តាមរយៈការធានាឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ ដោយបង្កើតបរិយាកាស ដែលមានសុវត្ថិភាពនិងអំណោយផលសម្រាប់សង្គមស៊ីវិល និងសហជីពព្រមទាំងជំរុញឱ្យមានការចូលរួមពេញលេញរបស់គណបក្សជំទាស់ក្នុងការបោះឆ្នោតឃុំ/សង្កាត់ ព្រឹទ្ធសភា និងរដ្ឋសភានៅអាណត្តិក្រោយ។ (កាណាដា)

៧ បញ្ឈប់រាល់ការបៀតបៀន និងជ្រៀតជ្រែកតាមទំនើងចិត្តទៅលើការប្រឆាំងផ្នែកនយោបាយ អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនការងារ ព្រមទាំងធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិនានា ដែលត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ដើម្បីកំណត់ព្រំដែននៃសេរីភាពសមាគម និងការប្រមូលផ្តុំ ដូចជា បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព។ (ហ្វាំងឡង់)

៨ អនុម័តនូវវិធានការចាំបាច់នានា ដើម្បីធានាសិទ្ធិរបស់អ្នកទាំងឡាយដែលធ្វើការដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ជាពិសេស អ្នកការពារសិទ្ធិមនុស្ស។ (អាហ្សង់ទីន)

## ចំណុចវឌ្ឍនភាព

ចាប់តាំងពីទទួលយកអនុសាសន៍ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបានវឌ្ឍនភាពលើចំណុចមួយចំនួនដូចខាងក្រោម៖

- ក្រសួងមហាផ្ទៃបានសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) អនុវត្តគម្រោង រយៈពេល ៣ ឆ្នាំ ដើម្បីពង្រឹងការចូលរួមរបស់ពលរដ្ឋ ការកសាងសមត្ថភាព និងកិច្ចសន្ទនាប្រកបដោយបរិយាបន្ន។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតក្រុមការងារដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រាជាច្រើននៃច្បាប់ស្តីពីសហជីព។

## ចំណុចត្រូវបន្តអនុវត្ត

ទោះបីជាទទួលបានវឌ្ឍនភាពមួយចំនួនក្តី តែរដ្ឋាភិបាលគួរបន្តអនុវត្តលើចំណុចមួយចំនួនទៀតដូចជា៖

- បន្តពិនិត្យ និងចុះឈ្មោះគណបក្សថ្មីៗ និងផ្តល់នីតិសម្បទាដល់គណបក្សនយោបាយដើម្បីឱ្យអ្នកនយោបាយដែលត្រូវបានហាមប្រាមធ្វើសកម្មភាពនយោបាយ អាចអនុវត្តសកម្មភាពនយោបាយរបស់ខ្លួនឡើងវិញ។
- បន្តពង្រឹងច្បាប់ លើកកម្ពស់ និងគោរពសិទ្ធិមនុស្ស។
- ពន្លឿនកិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់ពាក់ព័ន្ធ និងបំពេញនីតិវិធីនានាដើម្បីរដ្ឋសភាអនុម័ត។

ម.ស.ម.ក សូមរំឭកអំពីកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋាភិបាលក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងស្នើឱ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ដែលបានទទួលយកទាំងអស់ឱ្យបានមុនយូភីអ ជុំបន្ទាប់។ ម.ស.ម.ក ព្រមទាំងស្នើឱ្យរដ្ឋាភិបាលពិចារណាទទួលយកអនុសាសន៍ដែលកត់សម្គាល់ទាំងអស់នៅក្នុងជុំទីបួនផងដែរ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org
ខែកក្កដា ឆ្នាំ២០២៣
CC BY NC SA